ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ០០៧២ កសក/ក.សក

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងារអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មីនៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតក្រុមការងារអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | នុត ច័ន្ទសុខា | រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម | គឹម សុន | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣-លោកជំទាវ | យ៉េវ អាស៊ីគីន | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-ឯកឧត្តម | ចាន់ ហេង | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥-ឯកឧត្តម | យី កុសល | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៦-ឯកឧត្តម | ស្រី វុឌ្ឍី | អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| ៧-ឯកឧត្តម | គង់ រិាញ | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៨-ឯកឧត្តម | កែវ អូម៉ាលីស្ស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៩-ឯកឧត្តម | ង៉ិន ឆាយ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១០-ឯកឧត្តម | តាន់ ផាន់ណារ៉ា | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១១-ឯកឧត្តម | ពុំ សុថា | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល | សមាជិក |
| ១២-ឯកឧត្តម | ហ៊ឹម អូន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ១៣-លោក | សរ ចិត្រា | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤-លោក | យន សារ៉េត | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥-លោក | ម៉ឹក គឹមស្រួយ | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦-លោក | សួន សុវណ្ណ | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៧-លោក | ជា ច័ន្ទវាសនា | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៨-លោកស្រី | គង់ សុធីរី | ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិកា |
| ១៩-លោក | ទី ចាន់ណា | ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ២០-លោក | កុំ រ៉ា | ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ២១-លោក | ត្រី ម៉ះផល | ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះនៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ២២-លោក | ចៃ សាវុន | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ២.–**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- បង្កើនការស្នើសុំរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) លើបទល្មើសដែលមានហានិភ័យសម្អាតប្រាក់ខ្ពស់ ព្រមទាំងបទល្មើសធនធានធម្មជាតិ
- ផ្តល់មតិត្រឡប់ទៅ ស.ហ.ក អំពីប្រសិទ្ធភាពនៃការប្រើប្រាស់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ
- បង្កើនការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ពាក់ព័ន្ធធនធានធម្មជាតិ (បទល្មើសព្រៃឈើ និងសត្វព្រៃ)
- បង្កើនការស្វែងរកជានទ្រព្យសម្បត្តិ ដែលត្រូវអនុវត្តនៅពេលចាប់ផ្តើមដំបូងនៃការស៊ើបអង្កេតសំអាងនៃបទល្មើស
- ចងក្រងស្ថិតិនៃការស៊ើបអង្កេតសំអាងនៃបទល្មើស និងបទល្មើសសម្អាតប្រាក់លើធនធានធម្មជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

**ប្រការ៣.**_

ក្រុមការងារនេះ មានលេខាធិការដ្ឋានប្រចាំការ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ស្រី វុឌ្ឍី | អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម | គង់ វិាញ | អគ្គាធិការនៃអគ្គាធិការដ្ឋាន | អនុប្រធាន |
| ៣-លោក | យន សារ៉េត | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-លោក | សួន សុវណ្ណ | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិកអចិន្ត្រៃយ៍ |
| ៥-លោក | ត្រី ម៉ះផល | ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះនៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ៦-លោក | ចែ សាវុន | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក | អ៊ិត ភូម្រា | អនុប្រធាននាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់នៃរដ្ឋបាលព្រៃឈើ | សមាជិក |

**ប្រការ៤.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**_

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលព្រៃឈើ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- អនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ